ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍

* * * * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ /១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០០ ស្តីពីការកែសំរួលមុខងារ និងភារកិច្ច និងការបង្កើតក្រុមអ្នកច្បាប់ និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាននៃក្រសួងទេសចរណ៍
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០០៤ ។



www.pheakdeylaw.com

# សំ រេ ច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងផ្តល់ចំណាត់ថ្នាក់ដល់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ សំដៅបញ្ជាក់អំពីកំរិតគុណភាព សេវាកម្ម សំភារៈនិងគ្រឿងបំពាក់នៅតាមសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍អោយបានសមស្របតាមនិយាមអន្តរជាតិ ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តគ្រប់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣.-**

សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ គឺជាមូលដ្ឋានផ្គត់ផ្គង់សេវាកម្មស្នាក់នៅ មានលក្ខណៈជាបន្ទប់គ្រែ និងមានផ្តល់នូវសម្បទា និងសេវាផ្សេងៗទៀតទៅតាមប្រភេទ នៃមូលដ្ឋានសេវាកម្មស្នាក់នៅនីមួយៗដូចជា : សណ្ឋាគារ (Hotel) ម៉ូតែល (Motel) ឡូដ(Lodge) ប៊ីងហ្កាឡូ (Bungalow) សណ្ឋាគារអាផាតម៉ិន ( Hotel Apartment ) សណ្ឋាគារស៊្វីត (Suite Hotel) សណ្ឋាគាររីសត ( Resort Hotel ) ផ្ទះភ្ញៀវ (Guest House) កន្លែងបោះជំរុំទេសចរណ៍ ( Tourist Camping) ដូចមានក្នុងឧបសម្ព័ន្ធ៥ និងមូលដ្ឋានសេវាកម្មស្នាក់នៅផ្សេងៗទៀតដែលមានឧបនិស្ស័យក្នុងការបំរើភ្ញៀវទេសចរ ។

**មាត្រា ៤.-**

ការផ្តល់ចំណាត់ថ្នាក់នេះមិនត្រូវបានអនុវត្តលើមូលដ្ឋានសេវាកម្មស្នាក់នៅណាដែលមានលក្ខណៈសម្បត្តិ ឬសម្បទាមិនគ្រប់គ្រាន់ តាមល័ក្ខខ័ណ្ឌអប្បបរមានៃប្រព័ន្ធចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ ដូចជាផ្ទះសំណាក់ខ្នាតតូច ផ្ទះសំរាប់លំហែ ផ្ទះជួល ឬផ្ទះល្វែងជួលរយៈពេលវែង រយៈពេលខ្លី សំរាប់ប្រជាពលរដ្ឋ ឬជនបរទេស ។

**មាត្រា ៥.-**

ក្រសួងទេសចរណ៍មានភារកិច្ចរៀបចំវាយតំលៃនិងសំរេចផ្តល់ចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ ក្នុងព្រះរាជាណាចក្រកម្ពុជា ។



www.pheakdeylaw.com

## ជំពូកទី ២
## ការផ្តល់ចំណាត់ថ្នាក់

**មាត្រា ៦.-**

ក្រសួងទេសចរណ៍ត្រូវរៀបចំប្រព័ន្ធស្តង់ដាចំណាត់ថ្នាក់ និង គោលការណ៍ណែនាំសំរាប់វាយតំលៃផ្តល់ចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ ។ រាល់សណ្ឋាគារត្រូវមានចំណាត់ថ្នាក់ទៅតាមប្រព័ន្ធស្តង់ដាចំណាត់ថ្នាក់ដែលកំណត់ ដោយក្រសួងទេសចរណ៍ដូចមានក្នុងឧបសម្ព័ន្ធ១ ឧបសម្ព័ន្ធ២ ឧបសម្ព័ន្ធ៣ និងឧបសម្ព័ន្ធ៤ ។ ចំពោះសេវាកម្មស្នាក់នៅទេសចរណ៍ផ្សេងទៀត ត្រូវមានប្រព័ន្ធស្តង់ដាចំណាត់ថ្នាក់តាមការកំណត់របស់ក្រសួងទេសចរណ៍ ។

**មាត្រា ៧.-**

គោលការណ៍សំខាន់ៗ សំរាប់វិនិច្ឆ័យផ្តល់ចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍មាន :

- ទីតាំង ស្ថាបត្យកម្ម និងទិដ្ឋភាពទូទៅ ដោយរាប់បញ្ចូលទាំងគុណភាព និងល័ក្ខខ័ណ្ឌផ្នែកខាងក្រៅអាគារ ទស្សនីយភាព ទីសាធារណៈក្នុងអាគារ និងបន្ទប់ភ្ញៀវ
- ការបំពាក់សំភារៈ បរិក្ខារ ដោយរាប់បញ្ចូលផ្នែកម្រាល និងជញ្ជាំង វាំងនន អគ្គិសនីបំភ្លឺ ប្រព័ន្ធប្រើប្រាស់អគ្គិសនី គ្រឿងសង្ហារឹម ព័ត៌មាន និងទូរគមនាគមន៍
- អនាម័យ និងការថែទាំ ដោយរាប់បញ្ចូលបន្ទប់ភ្ញៀវ បន្ទប់ទឹក កន្លែងសាធារណៈ កន្លែងកំសាន្ត
- សេវា និងគុណភាពសេវា ដោយរាប់បញ្ចូលឯកសណ្ឋាន អាកប្បកិរិយារបស់បុគ្គលិកចំពោះភ្ញៀវការគ្រប់គ្រង និងទំនាក់ទំនងរវាងបុគ្គលិក និងភ្ញៀវ សុវត្ថិភាពនិងសន្តិសុខភ្ញៀវ
- សេវាកម្មផ្តល់ម្ហូបអាហារ ដោយប្រើប្រាស់ផលិតផលក្នុងស្រុកដែលមានគុណភាព និងអនាម័យរាប់បញ្ចូលភោជនីយដ្ឋាន ការបំរើអាហារដល់បន្ទប់ គុណភាពម្ហូបអាហារ ចំនួនមុខម្ហូប ការរៀបចំតុ និងពិធីផ្សេងៗ
- ភ្លេងប្រពៃណី និង របាំបុរាណខ្មែរ ។

**មាត្រា ៨.-**

សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ ដែលទទួលចំណាត់ថ្នាក់បាន លុះត្រាតែមានអាជ្ញាប័ណ្ណទេសចរណ៍ស្ថិតក្នុងសុពលភាព និងល័ក្ខខ័ណ្ឌតម្រូវដូចតទៅ :

- ត្រូវមានការចុះបញ្ជីពាណិជ្ជកម្ម
- អាគារសំណង់ត្រូវមានលិខិតអនុញ្ញាតនិងការទទួលស្គាល់ជាផ្លូវការ
- មានវិញ្ញាបនប័ត្រធានារ៉ាប់រង
- អាគារស្នាក់នៅត្រូវធានាសន្តិសុខ សុវត្ថិភាព បង្ការអគ្គិភ័យ
- ការពារបរិស្ថាន
- មានអនាម័យល្អ
- អនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិផ្សេងៗទៀតរបស់រដ្ឋ ។



www.pheakdeylaw.com

**មាត្រា ៩.-**

សញ្ញាសំគាល់ចំណាត់ថ្នាក់នៃសណ្ឋាគារត្រូវកំណត់ដោយរូបផ្កាយចាប់ពីថ្នាក់ ផ្កាយ១ រហូតដល់ ផ្កាយ៥ ដែលជាកំរិតខ្ពស់បំផុត តាមប្រព័ន្ធវាយតំលៃចំណាត់ថ្នាក់ ។ សញ្ញាសំគាល់ចំណាត់ថ្នាក់នៃសេវាកម្មស្នាក់នៅទេសចរណ៍ដទៃទៀតត្រូវកំណត់ដោយប្រកាសរបស់ក្រសួងទេសចរណ៍ ។

**មាត្រា ១០.-**

ផ្លាកសញ្ញាចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងទេសចរណ៍ ។

## ជំពូកទី ៣
## ការសុំចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍

**មាត្រា ១១.-**

អ្នកទទួលខុសត្រូវគ្រប់គ្រងត្រូវដាក់ពាក្យស្នើសុំចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍របស់ខ្លួននៅក្រសួងទេសចរណ៍ ដោយបំពេញបែបបទតាមគំរូពាក្យស្នើសុំ និងល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ៨ នៃអនុក្រឹត្យនេះ និង ល័ក្ខខ័ណ្ឌផ្សេងទៀតដែលតម្រូវដោយក្រសួងទេសចរណ៍ ។

## ជំពូកទី ៤
## នីតិវិធីនៃការរៀបចំ និងសុពលភាពចំណាត់ថ្នាក់

**មាត្រា ១២.-**

ក្រសួងទេសចរណ៍ត្រូវបង្កើតគណៈកម្មការរៀបចំ និងវាយតម្លៃចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ ហៅកាត់ថា **គ.រ.ច**។ **គ.រ.ច** ត្រូវមានការចូលរួមពីសមាសភាពផ្នែកឯកជនដែលមានការពាក់ព័ន្ធ ។ **គ.រ.ច** នេះត្រូវដឹកនាំដោយអគ្គនាយកជំនាញ និងមាននាយកដ្ឋានជំនាញជាលេខាធិការដ្ឋាន ។

**មាត្រា ១៣.-**

បន្ទាប់ពីបានទទួលពាក្យស្នើសុំត្រឹមត្រូវ គ.រ.ច ត្រូវចាត់តាំងក្រុមការងារ ចុះត្រួតពិនិត្យប្រមូលទិន្នន័យវាយតំលៃសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ យ៉ាងយូរម្ភៃ (២០)ថ្ងៃ នៃថ្ងៃធ្វើការ ។ ការបង់ថ្លៃសំរាប់ការចុះបំពេញការងារត្រួតពិនិត្យ និងវាយតំលៃរៀបចំចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងទេសចរណ៍ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។



www.pheakdeylaw.com

## មាត្រា ១៤.-

ការវាយតំលៃចំណាត់ថ្នាក់ អាចត្រូវធ្វើលើសពីមួយដងទៅតាមសំណូមពរចាំបាច់របស់អ្នកទទួលខុសត្រូវគ្រប់គ្រងសណ្ឋាគារ និង សេវាកម្មស្នាក់នៅទេសចរណ៍។

## មាត្រា ១៥.-

ក្រុមការងារនៃ គ.រ.ច ត្រូវពាក់ប័ណ្ណសំគាល់ពេលចុះត្រួតពិនិត្យសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ និង បង្ហាញដល់អ្នកទទួលខុសត្រូវគ្រប់គ្រងសណ្ឋាគារ នូវលិខិតឧទ្ទេសនាមរបស់ គ.រ.ច ។ ក្រុមការងារនៃ គ.រ.ច ត្រូវធ្វើកំណត់ហេតុ និងរបាយការណ៍អំពីលទ្ធផលនៃការងារត្រួតពិនិត្យ ដោយផ្តល់យោបល់លើចំណាត់ថ្នាក់ ផ្អែកតាមប្រព័ន្ធចំណាត់ថ្នាក់ជាមូលដ្ឋាន ។

## មាត្រា ១៦.-

គ.រ.ច ត្រូវពិនិត្យ ដោយផ្តល់ចំណាត់ថ្នាក់ក្នុងជំហានដំបូង ផ្អែកលើមូលដ្ឋានសំខាន់ៗ ដូចខាងក្រោម :

- សំណុំបែបបទសុំចំណាត់ថ្នាក់
- កំណត់ហេតុចុះត្រួតពិនិត្យ
- របាយការណ៍វាយតម្លៃរបស់ក្រុមការងារនៃ គ.រ.ច
- ឯកសារ និងព័ត៌មានផ្សេងៗទៀតដែលចាំបាច់ ។

## មាត្រា ១៧.-

គ.រ.ច ត្រូវចេញលិខិតជូនដំណឹងអំពីការវាយតម្លៃចំណាត់ថ្នាក់ជំហានដំបូងជូនអ្នកស្នើសុំក្នុងរយៈពេលម្ភៃ (២០) ថ្ងៃ នៃថ្ងៃធ្វើការយ៉ាងយូរក្រោយពីក្រុមការងារនៃ គ.រ.ច ចុះពិនិត្យ ។ ក្រោយរយៈពេលដប់ប្រាំ (១៥) ថ្ងៃ នៃថ្ងៃធ្វើការ នៃសេចក្តីជូនដំណឹងនេះ បើគ្មានការជំទាស់ជាលាយលក្ខណ៍អក្សរពីអ្នកស្នើសុំនោះទេ ការប្រកាសលទ្ធផលចំណាត់ថ្នាក់ជំហានដំបូង ត្រូវចាត់ទុកជាបានការ ។ ក្រសួងទេសចរណ៍ ត្រូវចេញសេចក្តីទទួលស្គាល់ និងផ្តល់ចំណាត់ថ្នាក់សំរេចជាផ្លូវការពីរដ្ឋមន្ត្រីក្រសួងទេសចរណ៍ មិនឱ្យលើសពីដប់ប្រាំ (១៥) ថ្ងៃ នៃថ្ងៃធ្វើការ។

## មាត្រា ១៨.-

អ្នកស្នើសុំចំណាត់ថ្នាក់មានសិទ្ធិធ្វើលិខិតតវ៉ាជំទាស់ ចំពោះលទ្ធផលនៃចំណាត់ថ្នាក់ជំហានដំបូងលើសណ្ឋាគារ ឬសេវាកម្ម ស្នាក់នៅទេសចរណ៍របស់ខ្លួន និងស្នើសុំវាយតម្លៃឡើងវិញមិនអោយហួសរយៈពេលដប់ប្រាំ (១៥) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលការជូនដំណឹងអំពីការវាយតម្លៃចំណាត់ថ្នាក់ជំហានដំបូង ដោយបញ្ជាក់ពីមូលហេតុច្បាស់លាស់ ។ ក្នុងករណីនេះ គ.រ.ច ត្រូវអនុវត្តតាមនីតិវិធីដូចមានចែងក្នុងមាត្រា ១៣ និង ១៧ នៃអនុក្រឹត្យនេះ ។


www.pheakdeylaw.com

**មាត្រា ១៩.-**

ក្នុងករណីសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ណាពុំអាចបំពេញបានតាមកំរិតប្រព័ន្ធស្តង់ដាអប្បបរមា ដូចមានកំណត់ក្នុងប្រព័ន្ធវាយតម្លៃចំណាត់ថ្នាក់របស់ក្រសួងទេសចរណ៍ នោះ គ.រ.ច ត្រូវធ្វើលិខិតឆ្លើយតប និងបញ្ជាក់អំពីមូលហេតុច្បាស់លាស់ជូនដល់អ្នកស្នើសុំ ។

**មាត្រា ២០.-**

ចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍មានសុពលភាពរយៈពេលពីរ (២)ឆ្នាំ ។ អ្នកទទួលខុសត្រូវគ្រប់គ្រងសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ ត្រូវដាក់ពាក្យសុំចំណាត់ថ្នាក់ឡើងវិញមុនពេលផុតសុពលភាពយ៉ាងតិច កៅសិប (៩០) ថ្ងៃ នៃថ្ងៃធ្វើការ ។ ចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ អាចត្រូវតម្លើងថ្នាក់ បញ្ចុះថ្នាក់ ព្យួរ ឬបដិសេធ ក្នុងរយៈពេលសុពលភាព ។

**មាត្រា ២១.-**

ការប្រើប្រាស់ចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ហួសសុពលភាព ឬធ្វើការផ្សព្វផ្សាយចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ ដោយគ្មានការទទួលស្គាល់ពីក្រសួងទេសចរណ៍ ត្រូវចាត់ទុកជាខុសច្បាប់ ។

## ជំពូកទី ៥
## ទោសប្បញ្ញត្តិ

**មាត្រា ២២.-**

អ្នកទទួលខុសត្រូវគ្រប់គ្រងសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ដែលប្រព្រឹត្តល្មើសនឹងមាត្រា ៦ មាត្រា ២១ នៃអនុក្រឹត្យនេះ ត្រូវពិន័យវដ្តចាលជាប្រាក់ចំនួនពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ៥ ០០០ ០០០ (ប្រាំលាន) រៀល ។

ក្នុងករណីសាមីខ្លួនមិនរាងចាល ត្រូវពិន័យជាប្រាក់ទ្វេដង ។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**មាត្រា ២៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។



www.pheakdeylaw.com

**មាត្រា ២៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ ត្រូវអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទការល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ២៤
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com

# ឧបសម្ព័ន្ធ ១

នៃអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៤
ស្តីពី ចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍

**ក្រសួងទេសចរណ៍**

**គណៈកម្មការរៀបចំចំណាត់ថ្នាក់សណ្ឋាគារ**

## ប្រព័ន្ធស្តង់ដារអប្បបរមា
## សំរាប់ចំណាត់ថ្នាក់សណ្ឋាគារកម្ពុជា

| ល,រ | បរិយាយ | ក្រោមផ្កាយ | ផ្កាយ ១ | ផ្កាយ ២ | ផ្កាយ ៣ | ផ្កាយ ៤ | ផ្កាយ ៥ |
|---|---|---|---|---|---|---|---|
| ១ | ទីតាំង ស្ថាបត្យកម្ម និង និជ្ជភាពខាងក្រៅ | | | | | | |
| ១-១ | ទីតាំងសណ្ឋាគារ | - មធ្យម | - មធ្យម<br>- ចរាចរងាយស្រួល | - មធ្យម<br>- ចរាចរងាយស្រួល | - ល្អបង្គួរ<br>- ចរាចរងាយស្រួល | - ល្អ<br>- ផៃទំាបានស្អាត<br>- ចរាចរងាយស្រួល | - ទីតាំងពិសេស<br>- ទិទ្ធភាព ល្អ<br>- ផៃទំាបានស្អាត<br>- ចរាចរងាយស្រួល |

១

www.pheakdeylaw.com

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១-២ | ក្លោងទ្វារ ដងផ្លូវចេញ-ចូលក្នុងសណ្ឋាគារនិងទិដ្ឋភាពរូមនៃសណ្ឋាគារ ( អាគារ ) | - មានការថែទាំល្អ<br>- មានរចនាបថខ្មែរ | - ស្អាត និងមានការថែទាំល្អ<br>- មានរចនាបថខ្មែរ | - ស្អាត និងមានការថែទាំល្អ<br>- មានរចនាបថខ្មែរ | - ផ្លូវធ្វើដំណើរងាយស្រួល<br>- រៀបចំបានសមរម្យពេលមានតំរូវការ<br>- ដំបូល និង ក្លោងទ្វារមានរចនាបថខ្មែរ | - ផ្លូវធ្វើដំណើរងាយស្រួល<br>- រៀបចំបានសមរម្យពេលមានតំរូវការដោយមានទេសភាពល្អ<br>- ដំបូល ក្លោងទ្វារ និងផ្នែកខាងក្រៅមានរចនាបថខ្មែរ | - ផ្លូវធ្វើដំណើរងាយស្រួល<br>-រៀបចំបានសមរម្យពេលមានតំរូវការដោយមានទេសភាពល្អប្រណិត<br>- ដំបូល ក្លោងទ្វារគ្រប់ច្រកចេញ-ចូល និងផ្នែកខាងក្រៅមានរចនាបថខ្មែរ |
| ១-៣ | សួនច្បារ និង ទិដ្ឋភាពរូម | | មានកន្លែងដាំរុក្ខជាតិ | មានកន្លែងដាំរុក្ខជាតិ | មានការរៀបចំបានល្អបង្គួរ | ធំទូលាយ និងមានការថែទាំ បានល្អ | រៀបចំយ៉ាងល្អប្រណិត និងមានការថែទាំបានល្អ |
| **២** | **ចំណតរថយន្ត** | | | | | | |
| ២-១ | ចំនួនប្រឡោះចតរថយន្ត | | ១៥% នៃចំនួនបន្ទប់សរុប | ១៥% នៃចំនួនបន្ទប់សរុប | ២០%នៃចំនួនបន្ទប់សរុប | ២៥% នៃចំនួនបន្ទប់សរុប | ៣០%នៃចំនួនបន្ទប់សរុប |
| ២-២ | ចំណតរថយន្ត ដែលមានបុគ្គលិកប្រចាំការនិងភ្លើងបំភ្លឺ | | | | X | X | X |
| ២-៣ | ចំណតរថយន្តដែលមានរបងការពារអោយមានសុវត្ថិភាព | | | | | X | X |
| ២-៤ | ប្រឡោះចំណតរថយន្តសំរាប់ជនពិការ | | | | | | X |
| **៣** | **កន្លែងទទួលភ្ញៀវ** (Reception Lobby) | | | | | | |



Ru

www.pheakdeylaw.com

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៣-១ | ទំហំផ្ទៃជាម៉ែត្រការ៉េតូចបំផុត | ៩ម²+១ ម² សំរាប់ចំនួនបន្ទប់ដែលលើស២០បន្ទប់គឺទំហំក្រឡាផ្ទៃតូចបំផុត ២០ ម² | ២០ម²+១ ម² សំរាប់ចំនួនបន្ទប់ដែលលើស២០បន្ទប់គឺទំហំក្រឡាផ្ទៃតូចបំផុត ៣០ ម² | ៣០ម²+១ ម² សំរាប់ចំនួនបន្ទប់ដែលលើស២០បន្ទប់ គឺទំហំក្រឡាផ្ទៃតូចបំផុត ៤០ ម² | ៤០ម²+១ ម² សំរាប់ចំនួនបន្ទប់ដែលលើស២០បន្ទប់គឺទំហំក្រឡាផ្ទៃតូចបំផុត ៨០ ម² | ៤០ម²+១ ម² សំរាប់ចំនួនបន្ទប់ដែលលើស២០បន្ទប់គឺទំហំក្រឡាផ្ទៃតូចបំផុត ១២០ ម² | ៤០ម²+១ ម² សំរាប់ចំនួនបន្ទប់ដែលលើស២០បន្ទប់ គឺទំហំក្រឡាផ្ទៃ តូចបំផុត ១៦០ម² |
| ៣-២ | កន្លែងទទួលភ្ញៀវដាច់ដោយឡែកពីកន្លែងលក់ដូរផ្សេងៗ ដូចជា ភោជនីយដ្ឋាន | | | X | X | X | X |
| ៣-៣ | ចំណុះកន្លែងអង្គុយសំរាប់ភ្ញៀវ | | ២ | ៤ | ៦ | ៨ | ១០ ដោយមានកន្លែងសំរាប់ដាក់តុសរសេរ |
| ៣-៤ | ចំនួនបន្ទប់តិចបំផុត | ៥ | ៥ | ១០ | ២០ | ៣០ | ៤០ |
| **៤** | **ជណ្តើរយោង (Lift)** | | | | | | |
| ៤-១ | ជណ្តើរយោងសំរាប់ភ្ញៀវ | | | | X | X | X |
| ៤-២ | -ជណ្តើរយោង (Lift) សំរាប់បំរើការក្នុងសណ្ឋាគារដាច់ដោយឡែក | | | | | X | X |
| **៥** | **ទំហំបន្ទប់ស្នាក់នៅ** | | | | | | |
| ៥-១ | -ផ្អែកទៅលើបន្ទប់សំរាប់ ២នាក់ រួមបញ្ចូលបន្ទប់ទឹក ដោយមិនរាប់បញ្ចូលយ៉ខាងក្រៅបន្ទប់ | ១២ ម² | ១៤ ម² | ១៨ ម² | ២១ ម² | ២៤ ម² | ២៨ ម² |



www.pheakdeylaw.com

| | | | | | | |
|---|---|---|---|---|---|---|
| ៥-២ | - ចំនួនអប្បបរមានៃទំហំបន្ទប់ស្វីត (Suite) | | | | ១ %តិចបំផុត៤៨ម$^2$ | ៥ %តិចបំផុត៥៦ម$^2$ |
| **៦** | **ឧបករណ៍សំភារៈបរិក្ខារប្រើប្រាស់និងសេវាក្នុងបន្ទប់ស្នាក់នៅ** | | | | | |
| ៦-១ | ម៉ាស៊ីនត្រជាក់ | | X | X | X | X | X |
| ៦-២ | ទឹកក្តៅ និងទឹកត្រជាក់ ២៤ ម៉ោង ( ទឹកស្អាតមានគុណភាពគ្រប់គ្រាន់ ) | | X | X | X | X | X |
| ៦-៣ | បន្ទប់មានអាងងូតទឹក | | | | តិចបំផុត ៥០% នៃបន្ទប់ | តិចបំផុត ៨០% នៃបន្ទប់ | គ្រប់បន្ទប់ទាំងអស់ |
| ៦-៤ | បន្ទប់មានផ្កាឈូកងូតទឹក | ផ្កាឈូក១ សំរាប់បន្ទប់ចំនួន ៤ | គ្រប់បន្ទប់ | គ្រប់បន្ទប់ | គ្រប់បន្ទប់ | | |
| ៦-៥ | ជាន់ពិសេស (Executive Floor) | | | | | | X |
| ៦-៦ | ទូរស័ព្ទក្នុងបន្ទប់ស្នាក់នៅ | | | X | X | X | X |
| ៦-៧ | ទូរស័ព្ទដាស់ពីដំណេក | | | | X | X | X |
| ៦-៨ | ការភ្ជាប់ប្រព័ន្ធ IDD ទៅតាមបន្ទប់ទាំងអស់ | | | | X | X | X |
| ៦-៩ | ទូទឹកកកតូចនៅក្នុងបន្ទប់ | | | | ៥០ % នៃបន្ទប់ | ៨០ % នៃបន្ទប់ | គ្រប់បន្ទប់ |
| ៦-១០ | ប្រអប់សុវត្ថិភាពសំរាប់ដាក់សំភារៈមានតំលៃរបស់ភ្ញៀវ | | | | | ៥០ % នៃបន្ទប់ | គ្រប់បន្ទប់ |
| ៦-១១ | សេវាបោកអ៊ុត | | | អាចមាន | X | X | X |



www.pheakdeylaw.com

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៦-១២ | សេវាបោកស្ងួត | | | | | X | X |
| ៦-១៣ | បោកពេលព្រឹក ពេលល្ងាច យកជល់បន្ទប់ | | | | | X | X |
| ៦-១៤ | សេវាផ្គត់ផ្គង់សារព័ត៌មាន | | | | សារព័ត៌មានក្នុងស្រុក | សារព័ត៌មានក្នុងស្រុក និង អន្តរជាតិ | សារព័ត៌មានក្នុងស្រុក និង អន្តរជាតិ |
| ៦-១៥ | ទឹកផឹក( មិនគិតថ្លៃ ) | X | X | X | X | X | X |
| ៦-១៦ | ផ្ដាំងអ៊ុត និង បន្ទះទម្រសំរាប់អ៊ុត | | | តាមសំណើរបស់ភ្ញៀវ | តាមសំណើរបស់ភ្ញៀវ | តាមសំណើរបស់ភ្ញៀវ | តាមសំណើរបស់ភ្ញៀវ |
| **៧** | **គ្រឿងសង្ហារិម និង សំភារៈបរិក្ខារប្រើប្រាស់ក្នុងបន្ទប់ស្នាក់នៅ** | | | | | | |
| ៧-១ | ទំហំគ្រែ (ទទឹង X បណ្ដោយ) | ១នាក់(០.៩x១.៨ម)<br>២នាក់(១.៤x១.៨ម) | ១នាក់(០.៩x ១.៨ម)<br>២ នាក់(១.៤x ១.៨ ម) | ១នាក់ (១x ១.៨ម)<br>២ នាក់(១.៤x ១.៨ ម) | ១នាក់(១.១ x១.៨ម)<br>២ នាក់(១.៤x ១.៨ ម) | ១នាក់(១.២x ២ ម)<br>២ នាក់(១.៨x ២ ម) | ១នាក់(១.៤០ x ២ម)<br>២ នាក់ (២x២ ម) |
| ៧-២ | តុតូចដាក់ជាប់គ្រែ | | ១ | ១ | ១សំរាប់គ្រែមួយ | ២ សំរាប់គ្រែ ២នាក់<br>៣ សំរាប់គ្រែភ្លោះ | ២ សំរាប់គ្រែ ២នាក់<br>៣ សំរាប់គ្រែភ្លោះ |
| ៧-៣ | តុនិងកៅអី សាឡុង | ១ | ១ | ១ | ១ សំរាប់គ្រែ ១ | ១ សំរាប់គ្រែ ១ | ១ សំរាប់គ្រែ ១ |
| ៧-៤ | ទូព្យួរខោអាវ និងប្រដាប់ព្យួរខោអាវ | X | X | X | X | X | X |
| ៧-៥ | ធ្នើរសំរាប់ដាក់វ៉ាលីស | | | X | X | X | X |
| ៧-៦ | កញ្ចក់ឆ្លុះមុខ | | | | X | X | កញ្ចក់ ១ ជំហរ |
| ៧-៧ | តុសរសេរមានកៅអី | | | X | X | X | X |



Ru

www.pheakdeylaw.com

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៧-៨ | ចង្កៀងនៅលើតុ | | | | | X | X |
| ៧-៩ | កៅអីទំនេរ | | | | | X | X |
| ៧-១០ | ទូសំរាប់ដាក់ទូទឹកកកតូច | | | | | X | X |
| ៧-១១ | គំនូសបំព្រួញច្រកចេញពេលមានអាសន្ន | X | X | X | X | X | X |
| ៧-១២ | ធុងសំរាម | X | X | X | X | X | X |
| ៧-១៣ | វាំងននពេលយប់ | X | X | X | X | X | X |
| ៧-១៤ | វាំងននពេលថ្ងៃ | X | X | X | X | X | X |
| ៧-១៥ | វាំងននក្រាស់ | | | | | X | X |
| ៧-១៦ | ទូទេស្សន៍ | | X | X | X | X | X |
| ៧-១៧ | ទូទស្សន៍ខ្សែកាប ឬ ប្រពន្ធ័ផ្កាយរណប | | | | | X | X |
| ៧-១៨ | ប្រពន្ធ័បញ្ជាអគ្គិសនី | | | X | X | ក្បែរគ្រែគេង | ប្រពន្ធ័បញ្ជាទំនើបក្បែរគ្រែគេង |
| ៧-១៩ | គ្រឿងសំភារៈបរិក្ខារផ្សេងទៀត | | | | | X | X |
| **៨** | **សំភារៈក្នុងបន្ទប់ទឹក** | | | | | | |
| ៨-១ | កញ្ចក់ឆ្លុះមានចង្កៀងបំភ្លឺ | X | X | X | X | X | X |
| ៨-២ | បន្ទប់ទឹកក្នុងបន្ទប់ស្នាក់នៅ | បន្ទប់ទឹក ១ សំរាប់បន្ទប់ស្នាក់នៅ ៤ | X | X | X | X | X |
| ៨-៣ | ប្រដាប់សំងួតសក់ | | | | | X | X |



www.pheakdeylaw.com

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៨-៤ | ទូរសព្ទ | | | | | X | X |
| ៨-៥ | មានសំលេងភ្លេង | | | | | | X |
| ៨-៦ | កន្លែងសំរាប់ងូតទឹក | ១ | ១ | ១ | ២ | ២ | ២ ប្តូរតាមសំណើ |
| ៨-៧ | កន្លែងដូតដៃ | | ១ | ១ | ២ | ២ | ២អាចផ្លាស់ប្តូរតាមសំណើ |
| ៨-៨ | កន្លែងដូតមុខ | | | | | | ២ |
| ៨-៩ | សំលៀកបំពាក់សំរាប់ប្រើប្រាស់មុន និងក្រោយពេលងូតទឹក | | | | | ១ សំរាប់ភ្ញៀវម្នាក់ | ១ សំរាប់ភ្ញៀវម្នាក់ |
| ៨-១០ | គ្រឿងសំអាតផ្សេងៗ | - សាប៊ូ | - សាប៊ូ<br>- ជង់អនាម័យ | - សាប៊ូ<br>- សាប៊ូកក់សក់<br>- ជង់អនាម័យ | - សាប៊ូ<br>- សាប៊ូកក់សក់<br>- ទឹកសាប៊ូ (Bath-gel)<br>- ជង់អនាម័យ | - សាប៊ូ<br>- សាប៊ូដុសខ្លួន (Bath soap)<br>~~- សាប៊ូកក់សក់~~<br>- ទឹកសាប៊ូ (Bath-gel)<br>- ជង់អនាម័យ<br>- មួកពាក់ពេលងូតទឹក<br>- ច្រាស និងថ្នាំដុសធ្មេញ | - សាប៊ូ<br>- សាប៊ូដុសខ្លួន (Bath soap )<br>- សាប៊ូកក់សក់ (Shampoo)<br>- ទឹកសាប៊ូ (Bath-gel)<br>- ថ្នាំរាវសំរាប់លាបខ្លួន (Body Lotion )<br>- ក្រាសសិតសក់<br>- ច្រាសនិងថ្នាំដុសធ្មេញ<br>- ជង់អនាម័យ<br>- មួកពាក់ពេលងូតទឹក<br>- មុលចេសសំរាប់ដេរ<br>- ប្រដាប់កោរពុកមាត់ |
| ៨-១១ | ជញ្ជីង | | | | | | X |
| ៨-១២ | ប្រដាប់ព្យួរខោអាវ | X | X | X | X | X | X |

៧

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៩ | **សេវាបំរើការស្នាក់នៅ** | | | | | | |
| ៩-១ | សេវាសំអាតបន្ទប់ស្នាក់នៅ | X | X | X | X | X | ២៤ ម៉ោង |
| ៩-២ | សេវាសំអាតទីធ្លាសាធារណៈរបស់សណ្ឋាគារ | X | X | X | X | X | ២៤ ម៉ោង |
| ៩-៣ | សេវាជញ្ជូនឥវ៉ាន់ភ្ញៀវ | | | | X | X | ២៤ ម៉ោង |
| ៩-៤ | គ្រែបន្ថែមតាមសំណើ | | | | X | X | X |
| ៩-៥ | បន្ទប់សំរាប់ជនពិការ | | | | | X | X |
| ៩-៦ | ការផ្លាស់ប្តូរកំរាលពូកស្រោមខ្នើយ និងសំភារៈក្នុងបន្ទប់ស្នាក់នៅ និងបន្ទប់ទឹក | រៀងរាល់ ២ ដងក្នុងមួយសប្តាហ៍ ឬពេលភ្ញៀវចេញ | រៀងរាល់ ២ ដងក្នុងមួយសប្តាហ៍ ឬ ពេលភ្ញៀវចេញ | រៀងរាល់២ថ្ងៃម្តង ឬពេលភ្ញៀវចេញ | រៀងរាល់២ថ្ងៃម្តង ឬពេលភ្ញៀវចេញ | រាល់ថ្ងៃ | រាល់ថ្ងៃ ឬតាមសំណើ |
| ៩-៧ | ការភ្ជាប់បណ្តាញអ៊ីនធឺណែតក្នុងបន្ទប់ស្នាក់នៅ | | | | | ៥០ % នៃបន្ទប់ | គ្រប់បន្ទប់ |
| ៩-៨ | បន្ទប់គូ (Connecting Room) | | | | | តិចបំផុត ៤ | តិចបំផុត ៨ |
| ៩-៩ | ការរៀបចំសេវាដឹកជញ្ជូន | | | | X | X | X |
| ៩-១០ | សេវារថយន្តទំនើបសំរាប់ជូនភ្ញៀវ (Limousine) | | | | | | X |
| ៩-១១ | សេវាប្រៃសណីយ៍ | | X | X | X | X | X |
| ៩-១២ | ទូសុវត្ថិភាពសំរាប់ដាក់សំភារៈបញ្ញើរបស់ភ្ញៀវនៅកន្លែងទទួលភ្ញៀវ | | X | X | X | X | X |
| **១០** | **ការតុបតែងលំអ** | | | | | | |



www.pheakdeylaw.com

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១០-១ | ការតុបតែងលំអ ក្នុងបន្ទប់ស្នាក់នៅ | ថែទាំជាប្រចាំ | សំភារៈសមរម្យសំរាប់ផាសុកភាព និង ការថែទាំជាប្រចាំ | សំភារៈគុណភាពល្អ សំរាប់ផាសុកភាព និងការថែទាំល្អ | សំភារៈគុណភាពខ្ពស់ ប្រកបដោយស្តង់ដាល្អ សំរាប់ផាសុកភាព និង ការថែទាំល្អ | ការរចនាតុបតែងផ្នែកខាងក្នុងដោយប្រើប្រាស់សំភារៈកំរិតខ្ពស់ ប្រកបដោយផាសុកភាពដែលរចនាឡើងដោយវិចិត្រករ និង មានការ ថែទាំល្អ | ការរចនាតុបតែងផ្នែកខាងក្នុងដោយប្រើប្រាស់សំភារៈប្រណិត សំបូរបែប ដែលរចនាដោយវិចិត្រករ និងមានការថែទាំល្អបំផុត |
| ១០-២ | ការដាក់តាំងវត្ថុសិល្បៈ ឬ ផ្ទាំងរូបភាពដែលឆ្លុះបញ្ចាំងពីវប្បធម៌ខ្មែរ នៅកន្លែងទទួលភ្ញៀវ របៀង | X | X | X | គុណភាពល្អ | គុណភាពខ្ពស់ ដាក់តាំងបានត្រឹមត្រូវ | គុណភាពប្រណិត ការដាក់តាំងបានត្រឹមត្រូវល្អប្រសើរ |
| **១១** | **សេវាម្ហូបអាហារ និង ភេសជ្ជៈ** | | | | | | |
| ១១-១ | ការបំរើអាហារពេលព្រឹកដល់បន្ទប់ស្នាក់នៅ | | | | | X | X |
| ១១-២ | មានអាហារប័ណ្ណតាមបន្ទប់ស្នាក់នៅ | | | | X | X | X |
| ១១-៣ | ការបំរើអាហារនិងភេសជ្ជៈដល់បន្ទប់ស្នាក់នៅ២៤ម៉ោង | | | | | | X |
| ១១-៤ | សេវាម្ហូបអាហារអប្បបរមា ដែលសមស្របនៅទីកន្លែងណាមួយក្នុងសណ្ឋាគារ | | X | | | | |



www.pheakdeylaw.com

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១១-៥ | ចំនួនភោជនីយដ្ឋានដែលមានចង្ក្រានដាច់ដោយឡែក | | | ១ | ១ | ២ សំរាប់ ១០០ បន្ទប់ ឡើងទៅ | ២សំរាប់ ១០០ បន្ទប់ ទៅ ២៥០ បន្ទប់ និង ៣សំរាប់ ២៥១ បន្ទប់ ឡើងទៅ |
| ១១-៦ | កន្លែងបំរើសេវាជុះដែលមានតន្ត្រីកំដរ | | | | | | X |
| ១១-៧ | បានីយដ្ឋានដែលមានផ្លូវចេញ-ចូលដោយឡែក | | | | | X | X |
| ១១-៨ | កំរាលតុ និង កន្សែងស្អាតប្រើសំរាប់អាហារទូទៅ | | | | | X | X |
| ១១-៩ | កំរាលតុ និង កន្សែងស្អាតប្រើសំរាប់អាហារពេលព្រឹក អាហារថ្ងៃត្រង់ និង អាហារពេលល្ងាចផ្សេងៗគ្នា | | | | | | X |
| ១១-១០ | ចំនួនកៅអី ក្នុងភោជនីយដ្ឋាន | | | សមាមាត្រទៅនឹងទំហំសណ្ឋាគារ | សមាមាត្រទៅនឹងទំហំសណ្ឋាគារ | អប្បបរមា ៤៥ % នៃ ចំនួនបន្ទប់សណ្ឋាគារ | អប្បបរមា ៥០ % នៃ ចំនួនបន្ទប់សណ្ឋាគារ និង បើកបំរើ ២៤ម៉ោង |
| ១១-១១ | ការតុបតែងលំអនិងសំភារៈបំពាក់ក្នុងភោជនីយដ្ឋាន | | | ស្អាត និង មានការថែទាំជាប្រចាំ | ស្អាត.បំពាក់សំភារៈល្អ តុបតែងបានសមរម្យ | - ស្អាត.បំពាក់សំភារៈល្អ<br>- មានគ្រឿងសង្ហារិម<br>- និងតុបតែងបានល្អ | ការសំអាត និងសំភារៈបំពាក់កំរិតខ្ពស់ និងមានការថែទាំបានល្អ មានគ្រឿងសង្ហារិមប្រណីត និង តុបតែងបានល្អ |



www.pheakdeylaw.com

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១១-១២ | កិរិតសេវាបំរើក្នុងភោជនីយដ្ឋាន | | | កិរិតធម្មតា | ស្តង់ដាលមធ្យម | មានមុខម្ហូបច្រើនសំរាប់ជ្រើសរើស និងសេវាល្អ | មុខម្ហូបមានកិរិតស្តង់ដាខ្ពស់ និង សំបូរបែបសំរាប់ជ្រើសរើសរួមទាំងស្រា និង ភេសជ្ជៈ |
| ១១-១៣ | បន្ទប់ពិសេស (Private Room) | | | | | | គ្រប់ភោជនីយដ្ឋាន |
| ១១-១៤ | មានបំរើម្ហូបក្នុងស្រុក | | | | តិចបំផុត ៤ មុខ | តិចបំផុត ៤ មុខ | មានមុខម្ហូបច្រើនសំរាប់ជ្រើសរើស |
| ១១-១៥ | អនាម័យ | គោរពតាមបទដ្ឋានបច្ចេកទេស | គោរពតាមបទដ្ឋានបច្ចេកទេស | គោរពតាមបទដ្ឋានបច្ចេកទេស | គោរពតាមបទដ្ឋានបច្ចេកទេស | គោរពតាមបទដ្ឋានបច្ចេកទេស | គោរពតាមបទដ្ឋានបច្ចេកទេស |
| ១១-១៦ | សណ្ឋាគារដែលប្រើប្រាស់ផលិតផលក្នុងស្រុក ដែលមានគុណភាព និង អនាម័យល្អ | X | X | X | X | X | X |
| **១២** | **សំភារៈបរិក្ខារសំរាប់ប្រជុំ សាលជប់លៀង** | | | | | | |
| ១២-១ | សំភារៈបរិក្ខារសំរាប់ប្រជុំ | | | | X | X | X |
| ១២-២ | បន្ទប់ពិសេសសំរាប់ការប្រជុំតូច និងមធ្យមដែលអាចផ្ទុកភ្ញៀវបាន ២០ នាក់ យ៉ាងតិច | | | | X | X | X |



www.pheakdeylaw.com

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១២-៣ | បន្ទប់ធំទូលាយសំរាប់ពិធីផ្សេងៗ | | | | | | X |
| ១២-៤ | សំភារៈបរិក្ខារសំរាប់សោតទស្សន៍ | | | | អប្បបរមា | សំភារៈបរិក្ខារគ្រប់គ្រាន់ | សំភារៈបរិក្ខារគ្រប់គ្រាន់ទំនើប ដែលមានបច្ចេកវិទ្យាខ្ពស់ |
| ១២-៥ | ការតុបតែងលំអក្នុងសាលប្រជុំ / សាលជប់លៀង | | | | គ្រឿងសង្ហារិមល្អ និងទាក់ទាញ | គ្រឿងសង្ហារិម និងសំភារៈបរិក្ខារគុណភាពខ្ពស់ | ការតុបតែងល្អប្រណិតគ្រឿងសង្ហារិម គុណភាពខ្ពស់ការពារសំលេង និងពន្លឺ |
| **១៣** | **ទីធ្លាសាធារណៈនៃសណ្ឋាគារ** | | | | | | |
| ១៣-១ | ច្រកចូល របៀង សាលធំ កន្លែងទទួលភ្ញៀវ ច្រកចេញ-ចូលផ្សេងៗ | អនុលោមទៅតាមបទដ្ឋានការពារសុវត្ថិភាព និង បង្ការអគ្គិភ័យ | អនុលោមទៅតាមបទដ្ឋានការពារសុវត្ថិភាព និង បង្ការអគ្គិភ័យ | អនុលោមទៅតាមបទដ្ឋានការពារសុវត្ថិភាពនិងបង្ការអគ្គិភ័យ | - អនុលោមទៅតាមបទដ្ឋានការពារសុវត្ថិភាព និង បង្ការអគ្គិភ័យ<br>- ការតុបតែងនិងទំហំស្របតាមចំនួនបន្ទប់សណ្ឋាគារ | - អនុលោមទៅតាមបទដ្ឋានការពារសុវត្ថិភាព និងបង្ការអគ្គិភ័យ<br>- មានគំនូសបង្ហាញនិងការតុបតែងល្អ ទំហំទូលាយប្រកបដោយផាសុកភាព និងចរាចរងាយស្រួល | - អនុលោមទៅតាមបទដ្ឋាន ការពារសុវត្ថិភាព ធំទូលាយ និង បង្ការអគ្គិភ័យ និងការតុបតែងល្អប្រណិតដែលមានកន្លែងសំរាប់សំរាកអាន និងសរសេរ |
| ១៣-២ | ច្រកចេញ-ចូលសំរាប់ជនពិការ | | | | | X | X |



www.pheakdeylaw.com

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១៣-៣ | ទេះកង់សំរាប់ជនពិការ | | | X | X | X | X |
| ១៣-៤ | បង្គន់សាធារណៈ | | -ស្អាតមានការថែទាំល្អ<br>-ដោយឡែកពីគ្នាសំរាប់ បុរស និង ស្ត្រី ដោយមានផ្លាកសញ្ញា | -ស្អាតមានការថែទាំល្អ<br>-ដោយឡែកពីគ្នាសំរាប់ បុរស និង ស្ត្រី ដោយមានផ្លាកសញ្ញា | -ស្អាតមានការថែទាំល្អ<br>-ដោយឡែកពីគ្នាសំរាប់ បុរស និង ស្ត្រី ដោយមានផ្លាកសញ្ញា | -ស្អាតមានការថែទាំល្អ<br>-ដោយឡែកពីគ្នាសំរាប់ បុរស និង ស្ត្រី ដោយមានផ្លាកសញ្ញា<br>-ជិតកន្លែងសាធារណៈ<br>- មានសំភារៈប្រើប្រាស់គ្រប់គ្រាន់ | -ស្អាតមានការថែទាំល្អ<br>-ដោយឡែកពីគ្នាសំរាប់ បុរស និង ស្ត្រី ដោយមានផ្លាកសញ្ញា<br>-ជិតកន្លែងសាធារណៈ<br>- មានសំភារៈប្រើប្រាស់គ្រប់គ្រាន់ជាប្រចាំ |
| ១៣-៥ | ទូរស័ព្ទសាធារណៈ | | | | | X | X |
| ១៣-៦ | មានប្រដាប់គោះធូលី (បញ្ឆេះ) | X | X | X | X | X | X |
| **១៤** | **មជ្ឈមណ្ឌលសេវាធុរកិច្ចក្នុងសណ្ឋាគារ** | | | | | | |
| ១៤-១ | សេវាទូរស័ព្ទអន្តរជាតិ | | ក្នុងការិយាល័យរួម | ក្នុងការិយាល័យរួម | ក្នុងការិយាល័យរួម | ក្នុងការិយាល័យដោយឡែក | ក្នុងការិយាល័យដោយឡែក |
| ១៤-២ | ការបញ្ជូន និង ទទួលសារ | | | ក្នុងការិយាល័យរួម | ក្នុងការិយាល័យរួម | ក្នុងការិយាល័យដោយឡែក | ក្នុងការិយាល័យដោយឡែក |
| ១៤-៣ | សេវាអ៊ីនធឺណែត | | | | ក្នុងការិយាល័យរួម | ក្នុងការិយាល័យដោយឡែក | ក្នុងការិយាល័យដោយឡែក |
| ១៤-៤ | សេវាលេខាធិការ | | | | | X | ក្នុងការិយាល័យដោយឡែក |
| **១៥** | **សេវាកំសាន្ត** | | | | | | |
| ១៥-១ | អាងហែលទឹក | | | | | X | X |
| ១៥-២ | ទីលានវាយកូនបាល់ក្នុងបរិវេណសណ្ឋាគារ | | | | | | X |



www.pheakdeylaw.com

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១៥-៣ | កន្លែងហាត់ប្រាណ | | | | | X | X |
| ១៥-៤ | ហាងលក់ទំនិញ | | | | សំភារៈប្រើប្រាស់ចាំបាច់ក្នុងបន្ទប់ទឹក និងសារព័ត៌មាន | ហាងលក់ទំនិញគ្រប់មុខ និង វត្ថុអនុស្សាវរីយ | មណ្ឌលលក់ទំនិញ |
| ១៥-៥ | ព័ត៌មានសំរាប់ភ្ញៀវ | មាន | ធ្វើរមានឯកសារផ្សព្វផ្សាយ | ធ្វើរមានឯកសារផ្សព្វផ្សាយ | - ធ្វើរមានឯកសារផ្សព្វផ្សាយ<br>- មានការផ្តល់ព័ត៌មាននៅកន្លែងទទួលភ្ញៀវ | - ធ្វើរមានឯកសារផ្សព្វផ្សាយសំបូរបែប និង មានសេវាផ្តល់ព័ត៌មានគ្រប់គ្រាន់ | កន្លែងព័ត៌មានដាច់ដោយឡែកនិងមានផ្តល់សេវាកក់ (Booking) |
| ១៥-៦ | កន្លែងកំសាន្តសំរាប់កុមារក្នុងសណ្ឋាគារ | | | | X | X | |
| ១៥-៧ | មានបន្ទប់សំរាប់កុមារលេងកំសាន្ត និងមានការមើលថែទាំ | | | | | | X |
| **១៦** | **បុគ្គលិក និងការគ្រប់គ្រង** | | | | | | |
| ១៦-១ | ឯកសណ្ឋានសណ្ឋាគារ | | X | X | X | X | X |
| ១៦-២ | ឯកសណ្ឋានមានលក្ខណៈជាខ្មែរ ( មួយចំនួន ) | | X | X | | | |
| ១៦-៣ | ឯកសណ្ឋានមានលក្ខណៈជាខ្មែរសំរាប់បុគ្គលិកដែលមានទំនាក់ទំនងផ្ទាល់ជាមួយភ្ញៀវ | | | | X | X | X |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១៦-៤ | បន្ទប់អាហារសំរាប់បុគ្គលិក | | | | X | X | X |
| ១៦-៥ | បន្ទប់ទឹក និងបន្ទប់ផ្លាស់សំលៀកបំពាក់សំរាប់បុគ្គលិក | X | X | X | X | X | X |
| ១៦-៦ | វត្តមានអ្នកគ្រប់គ្រងតាមផ្នែកពេលថ្ងៃ | | | X | X | X | X |
| ១៦-៧ | វត្តមានអ្នកគ្រប់គ្រងតាមផ្នែកពេលយប់ | | | | | X | X |
| ១៦-៨ | មានអ្នកទទួលភារៈកិច្ចគ្រប់គ្រងសណ្ឋាគារ ( Duty Manager ) | | | | | | X |
| ១៦-៩ | មានប័ណ្ណផ្តល់យោបល់របស់ភ្ញៀវ | | | | | X | X |
| **១៧** | **សេវាសុខភាព** | | | | | | |
| ១៧-១ | វេជ្ជបណ្ឌិត | តាមទូរស័ព្ទ | តាមទូរស័ព្ទ | តាមទូរស័ព្ទ | តាមទូរស័ព្ទ | តាមទូរស័ព្ទ | តាមទូរស័ព្ទ |
| ១៧-២ | ប្រអប់សង្គ្រោះបន្ទាន់ | X | X | X | X | នៅគ្រប់កន្លែង | នៅគ្រប់កន្លែង |
| **១៨** | **គ្រឿងប្រណីត និង របស់បុរាណខ្មែរ** | X | X | X | X | X | X |

\+ ***កំណត់សំគាល់*** :

- សរុបទាំងអស់មាន ១២៦ ចំណុច ត្រូវត្រួតពិនិត្យក្នុងសណ្ឋាគារនីមួយៗ
- សញ្ញា "X" : មានន័យថាត្រូវតែមាន



www.pheakdeylaw.com

# ឧបសម្ព័ន្ធ ២

នៃអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី ១១ ខែមិថុនា ឆ្នាំ ២០០៤
ស្តីពី ចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍

**ក្រសួងទេសចរណ៍**

**គណៈកម្មការរៀបចំចំណាត់ថ្នាក់សណ្ឋាគារ**

## តារាងពិន្ទុសំរាប់វាយតំលៃចំណាត់ថ្នាក់សណ្ឋាគារ

ឈ្មោះសណ្ឋាគារ : ..........................................................................

ឈ្មោះម្ចាស់-អ្នកគ្រប់គ្រង : ..............................................................

អាស័យដ្ឋានសណ្ឋាគារ : .................................................................

ថ្ងៃ ខែ ឆ្នាំ ត្រួតពិនិត្យ : .............................................................. ត្រួតពិនិត្យលើកទី:..................

| ល.រ | បរិយាយ | ពិន្ទុគំរូ | ពិន្ទុពិត | ផ្សេងៗ |
|---|---|---|---|---|
| ១. | **ទីតាំងសណ្ឋាគារ ស្ថាបត្យកម្ម និង ទិដ្ឋភាពទូទៅ** | | | |
| ១-១ | + ទីតាំងសណ្ឋាគារ | | | |
| | - ទីតាំងពិសេស | ៣០ | | |
| | - ល្អ | ២៥ | | |
| | - ល្អបង្គួរ | ២០ | | |
| | - មធ្យម | ១០ | | |
| ១-២ | + ក្លោងទ្វារ ផងផ្លូវចេញ-ចូលក្នុងសណ្ឋាគារ និងទិដ្ឋភាពរួមនៃសណ្ឋាគារ ( អាគារ ) | | | |



www.pheakdeylaw.com

| | | | | |
|---|---|---|---|---|
| | - មានលក្ខណៈជាតិ ស្ថាបត្យកម្ម និងរចនាបថខ្មែរ | ១០ | | |
| | - ផ្លាកឈ្មោះសណ្ឋាគារអក្សរខ្មែរ ធំជាងអក្សរបរទេស | ១០ | | |
| | - លក្ខណៈធម្មតា មានការរៀបចំបានល្អ | ៥ | | |
| ១-៣ | + សួនច្បារ និងទិដ្ឋភាពរួម | | | |
| | - ធំទូលាយរៀបចំបានល្អប្រណិត និងមានការថែទាំល្អជាប្រចាំ | ១៥ | | |
| | - រៀបចំ និងថែរក្សាបានល្អសមរម្យ | ១០ | | |
| | - មានកន្លែងដាំរុក្ខជាតិ រៀបចំបានសមរម្យ | ៥ | | |
| ២. | **ចំណតរថយន្ត** | | | |
| ២-១ | + ចំនួនប្រឡោះចតរថយន្ត | | | |
| | - ៣០ % ឡើង នៃចំនួនបន្ទប់ | ១០ | | |
| | - ២៥ % ឡើង នៃចំនួនបន្ទប់ | ៨ | | |
| | - ២០% ឡើង នៃចំនួនបន្ទប់ | ៦ | | |
| | - ១៥% ឡើង នៃចំនួនបន្ទប់ | ៤ | | |
| | - ក្រោម ១៥ % នៃចំនួនបន្ទប់ | ២ | | |
| ២-២ | + មានបុគ្គលិកប្រចាំការ និងភ្លើងបំភ្លឺ | ៣ | | |
| ២-៣ | + មានរបងការពារ សុវត្ថិភាព | ៣ | | |
| ២-៤ | + ចំណតរថយន្តសំរាប់ជនពិការ | ២ | | |
| ៣. | **កន្លែងទទួលភ្ញៀវ** ( Reception / lobby ) | | | |
| ៣-១ | + ទំហំផ្ទៃជា ម$^{២}$ តូចបំផុត | | | |
| | - ១៦០ ម$^{២}$ ឡើងទៅ | ១០ | | |
| | - ១២០ ម$^{២}$ ឡើងទៅ | ៨ | | |
| | - ៨០ ម$^{២}$ ឡើងទៅ | ៦ | | |
| | - ៤០ ម$^{២}$ ឡើងទៅ | ៤ | | |
| | - ៣០ ម$^{២}$ ឡើងទៅ | ៣ | | |
| | - ២០ ម$^{២}$ ឡើងទៅ | ២ | | |

www.pheakdeylaw.com

| | | | | |
|---|---|---|---|---|
| ៣-២ | + កន្លែងទទួលភ្ញៀវ | | | |
| | - ដាច់ដោយឡែកពីកន្លែងលក់ដូរ | ៤ | | |
| | - លាយឡំគ្នាជាមួយកន្លែងលក់ដូរ (ដូចជា ភោជនីយដ្ឋាន ឬកន្លែងលក់វត្ថុអនុស្សាវរីយ៍ ) | ២ | | |
| ៣-៣ | + ចំណុះកន្លែងអង្គុយសំរាប់ភ្ញៀវ | | | |
| | - ១០ កន្លែងឡើង | ៦ | | |
| | - ៨ កន្លែងឡើង | ៥ | | |
| | - ៦ កន្លែងឡើង | ៤ | | |
| | - ៤ កន្លែងឡើង | ៣ | | |
| | - ២ កន្លែងឡើង | ២ | | |
| ៣-៤ | + ចំនួនបន្ទប់ | | | |
| | - ច្រើនជាង ២០០ បន្ទប់ | ៣០ | | |
| | - ១០១ - ២០០ បន្ទប់ | ២៥ | | |
| | - ៥១ - ១០០ បន្ទប់ | ១៥ | | |
| | - ៥ - ៥០ បន្ទប់ | ១០ | | |
| ៤. | **ជណ្តើរយោង** ( Lift ) | | | |
| ៤-១ | + ជណ្តើរយោងសំរាប់ភ្ញៀវ | ៥ | | |
| ៤-២ | + ជណ្តើរយោង សំរាប់បំរើការក្នុងសណ្ឋាគារដាច់ដោយឡែក | ៥ | | |
| ៥. | **ទំហំបន្ទប់ស្នាក់នៅ** | | | |
| ៥-១ | + បន្ទប់សំរាប់ ២នាក់ (គិតបញ្ចូលបន្ទប់ទឹក មិនគិតបញ្ចូលយ៉ខាងក្រៅ ) | | | |
| | - ២៨ ម$^{២}$ ឡើងទៅ | ១០ | | |
| | - ២៤ ម$^{២}$ ឡើងទៅ | ៨ | | |
| | - ២១ ម$^{២}$ ឡើងទៅ | ៦ | | |
| | - ១៨ ម$^{២}$ ឡើងទៅ | ៤ | | |
| | - ១៤ ម$^{២}$ ឡើងទៅ | ២ | | |



Ru

www.pheakdeylaw.com

| | | | | | |
|---|---|---|---|---|---|
| ៥-២ | + ចំនួនអប្បបរមានៃទំហំបន្ទប់ស្វ៊ីត (Suite) | | | | |
| | - ៥ % តិចបំផុត ( ទំហំបន្ទប់ស្វ៊ីត ៥៦ ម² ) | ៤ | | | |
| | - ១ % តិចបំផុត ( ទំហំបន្ទប់ស្វ៊ីត ៤៨ ម² ) | ២ | | | |
| ៦. | **ឧបករណ៍សំភារៈបរិក្ខារប្រើប្រាស់ និងសេវាក្នុងបន្ទប់ស្នាក់នៅ** | | | | |
| ៦-១ | + ម៉ាស៊ីនត្រជាក់ | | | | |
| | - ១០០ % នៃចំនួនបន្ទប់ | ១០ | | | |
| | - ៧៥ % ឡើង នៃចំនួនបន្ទប់ | ៨ | | | |
| | - ៥០ % ឡើង នៃចំនួនបន្ទប់ | ៦ | | | |
| | - ២៥ % ឡើង នៃចំនួនបន្ទប់ | ៣ | | | |
| ៦-២ | + ទឹកក្តៅ និងទឹកត្រជាក់ ២៤ ម៉ោង ( ទឹកស្អាតមានគុណភាពគ្រប់គ្រាន់ ) | ៥ | | | |
| ៦-៣ | + បន្ទប់មានអាងងូតទឹក | | | | |
| | - ១០០ % នៃបន្ទប់ស្នាក់នៅ | ១០ | | | |
| | - ៨០ % ឡើងទៅនៃបន្ទប់ស្នាក់នៅ | ៨ | | | |
| | - ៥០ % ឡើងទៅនៃបន្ទប់ស្នាក់នៅ | ៦ | | | |
| ៦-៤ | + បន្ទប់មានផ្កាឈូកសំរាប់ងូតទឹក ( គ្រប់បន្ទប់ ) | ៥ | | | |
| ៦-៥ | + ជាន់ពិសេស (Executive Floor) | ៥ | | | |
| ៦-៦ | + ទូរស័ព្ទក្នុងបន្ទប់ស្នាក់នៅ | | | | |
| | - ១០០ % នៃចំនួនបន្ទប់ស្នាក់នៅ | ៨ | | | |
| | - ៧៥ % ឡើងទៅនៃចំនួនបន្ទប់ស្នាក់នៅ | ៦ | | | |
| | - ៥០ % ឡើងទៅនៃចំនួនបន្ទប់ស្នាក់នៅ | ៤ | | | |
| | - ២៥ % ឡើងទៅនៃចំនួនបន្ទប់ស្នាក់នៅ | ២ | | | |
| ៦-៧ | + ទូរស័ព្ទដាស់ពីដំណេក | ៣ | | | |
| ៦-៨ | + ការភ្ជាប់ប្រព័ន្ធ IDD ទៅតាមបន្ទប់ទាំងអស់ | ៥ | | | |
| ៦-៩ | + ទូទឹកកក | | | | |
| | - ១០០ % នៃចំនួនបន្ទប់ស្នាក់នៅ | ១០ | | | |
| | - ៨០ % ឡើងទៅនៃចំនួនបន្ទប់ស្នាក់នៅ | ៨ | | | |



Ru

www.pheakdeylaw.com

| | | | | |
|---|---|---|---|---|
| | - ៥០ % ឡើងទៅនៃចំនួនបន្ទប់ស្នាក់នៅ | ៦ | | |
| ៦-១០ | + ប្រអប់សុវត្ថិភាពសំរាប់ដាក់សំភារៈមានតំលៃរបស់ភ្ញៀវ | | | |
| | - ១០០ % នៃចំនួនបន្ទប់ស្នាក់នៅ | ៨ | | |
| | - ៥០ % ឡើងទៅនៃចំនួនបន្ទប់ស្នាក់នៅ | ៤ | | |
| ៦-១១ | + សេវាបោកអ៊ុត | ២ | | |
| ៦-១២ | + សេវាបោកស្ងួត | ២ | | |
| ៦-១៣ | + បោកពេលព្រឹក ពេលល្ងាច យកដល់បន្ទប់ | ២ | | |
| ៦-១៤ | + សេវាផ្គត់ផ្គង់សារព័ត៌មាន | ២ | | |
| ៦-១៥ | + ទឹកផឹក ( មិនគិតថ្លៃ ) | ២ | | |
| ៦-១៦ | + ឆ្នាំងអ៊ុត និង បន្ទះទម្រ សំរាប់អ៊ុត | ២ | | |
| ៧. | **គ្រឿងសង្ហារិម និង សំភារៈបរិក្ខារប្រើប្រាស់ក្នុងបន្ទប់ស្នាក់នៅ** | | | |
| ៧-១ | + ទំហំគ្រែ ( សំរាប់ ១នាក់ ) | | | |
| | - ១.២ម x ២ ម ឡើងទៅ | ៦ | | |
| | - ០.៩ ម x ១.៨ ម ឡើងទៅ | ៣ | | |
| | + ទំហំគ្រែ ( សំរាប់ ២នាក់ ) | | | |
| | - ១.៨ ម x ២ ម ឡើងទៅ | ៦ | | |
| | - ១.៤ម x ១.៨ ម ឡើងទៅ | ៣ | | |
| ៧-២ | + តុតូចដាក់ជាប់គ្រែ | ២ | | |
| ៧-៣ | + តុនិងកៅអីសាឡុង | ២ | | |
| ៧-៤ | + ទូព្យួរខោអាវ និងប្រដាប់ព្យួរខោអាវ | ១ | | |
| ៧-៥ | + ធ្នើរសំរាប់ដាក់វ៉ាលីស | ១ | | |
| ៧-៦ | + កញ្ចក់ឆ្លុះមុខ | | | |
| | - កញ្ចក់ឆ្លុះមួយជំហរ | ២ | | |
| | - កញ្ចក់ឆ្លុះធម្មតា | ១ | | |
| ៧-៧ | + តុសរសេរមានកៅអី | ២ | | |
| ៧-៨ | + ចង្កៀងនៅលើតុ | ១ | | |
| ៧-៩ | + កៅអីទំរេត | ២ | | |



Ru

www.pheakdeylaw.com

| | | | | |
|---|---|---|---|---|
| ៧-១០ | + ទូសំរាប់ដាក់ទូទឹកកកតូច | ១ | | |
| ៧-១១ | + គំនូសបំព្រួញច្រកចេញ ពេលមានអាសន្ន | ២ | | |
| ៧-១២ | + ធុងសំរាម | ១ | | |
| ៧-១៣ | + វាំងននពេលយប់ | ២ | | |
| ៧-១៤ | + វាំងននពេលថ្ងៃ | ២ | | |
| ៧-១៥ | + វាំងននក្រាស់ | ២ | | |
| ៧-១៦ | + ទូរទស្សន៍ | | | |
| | - ១០០ % នៃចំនួនបន្ទប់ស្នាក់នៅ | ១០ | | |
| | - ៧៥ % ឡើងទៅនៃចំនួនបន្ទប់ស្នាក់នៅ | ៨ | | |
| | - ៥០ % ឡើងទៅនៃចំនួនបន្ទប់ស្នាក់នៅ | ៦ | | |
| | - ២៥ % ឡើងទៅនៃចំនួនបន្ទប់ស្នាក់នៅ | ៤ | | |
| ៧-១៧ | + ប្រើប្រព័ន្ធផ្កាយរណប ឬទូរទស្សន៍ខ្សែកាប | ៥ | | |
| | - VTR | ៣ | | |
| ៧-១៨ | + ប្រព័ន្ធបញ្ជាអគ្គិសនី | | | |
| | - ដាក់ក្បែរគ្រែដោយមានប្រព័ន្ធបញ្ជាទំនើប | ៥ | | |
| | - បញ្ជាធម្មតា | ២ | | |
| ៧-១៩ | គ្រឿងសំភារៈបរិក្ខារផ្សេងទៀត | | | |
| | + ក្រណាត់ជូតជើង | ១ | | |
| | + ប្រដាប់គោះបារី | ១ | | |
| | + ច្រាសដុសស្បែកជើង និងថ្នាំ | ១ | | |
| | - សេវាខាត់ស្បែកជើង | ១ | | |
| | + គន្លឹះទ្វារមានភ្ជាប់ដោយច្រវ៉ាក់ | ២ | | |
| | + សោទ្វារប្រើកាត | ៣ | | |
| | + ទ្វារមានកែវពង្រីកមើលចេញក្រៅ | ២ | | |
| | + សឺមីដាក់ឯកសារ | | | |
| | - ក្រដាស និងប៊ិច | ១ | | |
| | - ផែនទី | ១ | | |
| | - កាសែត ទស្សនាវដ្តី | ១ | | |
| | - តារាងព័តិមានផ្សេងៗ | ១ | | |



www.pheakdeylaw.com

| | | | | |
|---|---|---|---|---|
| | + ពូក កំរាលពូក ខ្នើយ ភួយ | | | |
| | - ស្អាត គុណភាពខ្ពស់ | ១០ | | |
| | - គុណភាពល្អ | ៨ | | |
| | - គុណភាពល្អបង្គួរ | ៦ | | |
| | - គុណភាពមធ្យម | ៤ | | |
| | + ប៉ាន់តែ ពែង កែវ បំពង់ទឹកក្តៅ | ២ | | |
| | + ស្បែកជើង ( ប្រើក្នុងបន្ទប់ស្នាក់នៅ ) | ១ | | |
| | + ថង់ដេរប៉ាក់ | ១ | | |
| | + ប្រដាប់ប្រើប្រាស់ផ្សេងទៀត | ២ | | |
| | + គុណភាពសំភារៈ បរិក្ខារប្រើប្រាស់ (គ្រឿងឈើ ក្រណាត់ អគ្គិសនី ព័រសីខ្សែន គ្រឿងកែវ និងប្រភេទផ្សេងទៀត) | | | |
| | - ល្អប្រណិត និងគុណភាពខ្ពស់ | ២០ | | |
| | - គុណភាពល្អ | ១៥ | | |
| | - គុណភាពល្អបង្គួរ | ១០ | | |
| | - គុណភាពមធ្យម | ៥ | | |
| | + ការរៀបចំតុបតែងឧបករណ៍សំភារៈប្រើប្រាស់ក្នុងបន្ទប់ស្នាក់នៅ | | | |
| | - មានសំភារៈបរិក្ខារច្រើនប្រភេទរៀបចំតុបតែងបានល្អ | ១៥ | | |
| | - សំភារៈបរិក្ខារប្រើប្រាស់រៀបចំមានរបៀបត្រឹមត្រូវ | ១០ | | |
| | + សំភារៈតុបតែងក្នុងបន្ទប់ស្នាក់នៅបង្ហាញនូវអត្តសញ្ញាណជាតិ | ១០ | | |
| ៨- | **សំភារៈក្នុងបន្ទប់ទឹក** | | | |
| ៨-១ | + កញ្ចក់ឆ្លុះមានចង្កៀងបំភ្លឺ | ២ | | |
| ៨-២ | + បន្ទប់ទឹកក្នុងបន្ទប់ស្នាក់នៅ | ៣ | | |
| ៨-៣ | + ប្រដាប់សំងួតសក់ | ១ | | |
| ៨-៤ | + ទូរស័ព្ទ | ២ | | |



Ru

www.pheakdeylaw.com

| | | | | |
|---|---|---|---|---|
| ៨-៥ | + មានសំលេងភ្លេង | ២ | | |
| ៨-៦ | + កន្លែងសំរាប់ងូតទឹក | | | |
| | - ២ ប្អូរតាមការស្នើ | ២ | | |
| | - ១ ធម្មតា | ១ | | |
| ៨-៧ | + កន្លែងជូតដៃ | ១ | | |
| ៨-៨ | + កន្លែងជូតមុខ | ១ | | |
| ៨-៩ | + សំលៀកបំពាក់សំរាប់ប្រើប្រាស់មុន និងក្រោយពេលងូតទឹក | ២ | | |
| ៨-១០ | + គ្រឿងសំអាតផ្សេងៗ | | | |
| | - សាប៊ូដុសខ្លួន | ១ | | |
| | - សាប៊ូកក់សក់ | ១ | | |
| | - សាប៊ូ ( bath-gel ) | ១ | | |
| | - មួកពាក់ពេលងូតទឹក | ១ | | |
| | - ច្រាស និងថ្នាំដុសធ្មេញ | ១ | | |
| | - ក្រាសសិតសក់ | ១ | | |
| | - ប្រដាប់កោរពុកមាត់ | ១ | | |
| | - ក្រដាសជូតដៃ | ១ | | |
| | - ថ្នាំរាវសំរាប់លាបខ្លួន ( body lotion ) | ១ | | |
| | - ថង់អនាម័យ | ១ | | |
| ៨-១១ | + ជញ្ជីង | ១ | | |
| ៨-១២ | + ប្រដាប់ព្យួរខោអាវ | ១ | | |
| | + ការរៀបចំតុបតែង និងគុណភាពបន្ទប់ទឹក | | | |
| | - ស្អាត គុណភាពពិសេស | ២០ | | |
| | - ស្អាត គុណភាពល្អ | ១៥ | | |
| | - គុណភាពល្អបង្គួរ | ១០ | | |
| | - គុណភាពមធ្យម | ៥ | | |
| ៩. | **សេវាបំពីការស្នាក់នៅ** | | | |
| ៩-១ | + សេវាសំអាតបន្ទប់ស្នាក់នៅ | | | |



www.pheakdeylaw.com

| | | | | |
|---|---|---|---|---|
| | - ២៤ ម៉ោង | ១០ | | |
| | - មួយថ្ងៃម្តង | ៥ | | |
| ៩-២ | + សេវាសំអាតទីធ្លាសាធារណៈ របស់សណ្ឋាគារ | | | |
| | - ២៤ ម៉ោង | ១០ | | |
| | - មួយថ្ងៃម្តង | ៥ | | |
| ៩-៣ | + សេវាជញ្ជូនឥវ៉ាន់ភ្ញៀវ | | | |
| | - សេវា ២៤ ម៉ោង | ១០ | | |
| | - សេវាធម្មតា | ៥ | | |
| ៩-៤ | + គ្រែបន្ថែមតាមសំណើ | ៥ | | |
| ៩-៥ | + បន្ទប់សំរាប់ជនពិការ | ៣ | | |
| ៩-៦ | + ការផ្លាស់ប្តូរកំរាលពូក ស្រោមខ្នើយ និងសំភារៈ ក្នុងបន្ទប់ស្នាក់នៅ និងបន្ទប់ទឹក | | | |
| | - រាល់ថ្ងៃ ឬតាមសំណើ | ២០ | | |
| | - រាល់ថ្ងៃ | ១៥ | | |
| | - រៀងរាល់ ២ថ្ងៃម្តង ឬពេលភ្ញៀវចេញ | ១០ | | |
| | - រៀងរាល់ ២ដងក្នុង ១សប្តាហ៍ ឬពេលភ្ញៀវចេញ | ៥ | | |
| ៩-៧ | + ការភ្ជាប់បណ្តាញអ៊ិនធឺណែតក្នុងបន្ទប់ | | | |
| | - គ្រប់បន្ទប់ | ១០ | | |
| | - ៥០ % ឡើងទៅនៃបន្ទប់ស្នាក់នៅ | ៥ | | |
| ៩-៨ | + បន្ទប់គូ ( Connecting rooms ) | | | |
| | - តិចបំផុត ៨ | ៤ | | |
| | - តិចបំផុត ៤ | ២ | | |
| ៩-៩ | + ការរៀបចំសេវាដឹកជញ្ជូន | ៥ | | |
| ៩-១០ | + សេវារថយន្តទំនើបសំរាប់ជូនភ្ញៀវ | ១០ | | |
| ៩-១១ | + សេវាប្រៃសណីយ៍ | ៣ | | |
| ៩-១២ | + ទូសុវត្ថិភាពសំរាប់ដាក់សំភារៈបញ្ញើរបស់ភ្ញៀវ នៅកន្លែងទទួលភ្ញៀវ | ៥ | | |
| | + កំរិតសេវាបំរើភ្ញៀវ | | | |
| | - សេវាពេញលេញ ( Full Service ) | ២០ | | |



www.pheakdeylaw.com

| | | | | |
|---|---|---|---|---|
| | - សេវាមធ្យម ( Moderate Service ) | ១៥ | | |
| | - សេវាមានកំរិត ( Limited Service ) | ១០ | | |
| **១០.** | **ការតុបតែងលំអ** | | | |
| ១០-១ | + ការតុបតែងលំអក្នុងបន្ទប់ភ្ញៀវស្នាក់នៅ | | | |
| | - ល្អប្រណិត | ២០ | | |
| | - ល្អ | ១៥ | | |
| | - ល្អបង្គួរ | ១០ | | |
| | - មធ្យម | ៥ | | |
| ១០-២ | + ការដាក់តាំងវត្ថុសិល្បៈ ឬផ្ទាំងរូបភាពដែលឆ្លុះបញ្ចាំងពីវប្បធម៌ខ្មែរ នៅកន្លែងទទួលភ្ញៀវ របៀង | ១០ | | |
| **១១.** | **សេវាម្ហូបអាហារ និងភេសជ្ជៈ** | | | |
| ១១-១ | + ការបំរើអាហារពេលព្រឹកដល់បន្ទប់ស្នាក់នៅ | ៥ | | |
| ១១-២ | + មានអាហារប័ណ្ណតាមបន្ទប់ស្នាក់នៅ | ៣ | | |
| ១១-៣ | +ការបំរើអាហារ និងភេសជ្ជៈដល់បន្ទប់ស្នាក់នៅ ២៤ម៉ោង | ៥ | | |
| ១១-៤ | + សេវាម្ហូបអាហារអប្បបរមាដែលសមស្រប នៅទីកន្លែង ណាមួយក្នុងសណ្ឋាគារ | ៣ | | |
| ១១-៥ | +ចំនួនភោជនីយដ្ឋាន មានចង្ក្រានដាច់ដោយឡែក | | | |
| | - ភោជនីយដ្ឋាន ១ | ៥ | | |
| | - ភោជនីយដ្ឋាន ២ ឡើងទៅ | ១០ | | |
| ១១-៦ | + កន្លែងបំរើភេសជ្ជៈមានតន្ត្រីកំដរ | ៥ | | |
| ១១-៧ | + បានីយដ្ឋានដែលមានផ្លូវចេញ-ចូលដោយឡែក | ៣ | | |
| ១១-៨ | + កំរាលតុ និងកន្សែងស្អាតប្រើសំរាប់អាហារទូទៅ | ៣ | | |
| ១១-៩ | + កំរាលតុ និងកន្សែងស្អាតប្រើសំរាប់អាហារពេលព្រឹក ថ្ងៃត្រង់ និងល្ងាចផ្សេងៗគ្នា | ៥ | | |
| ១១-១០ | + ចំនួនកៅអីក្នុងភោជនីយដ្ឋាន | | | |
| | - ៥០ % ឡើងទៅនៃចំនួនបន្ទប់ស្នាក់នៅ និងបំរើ ២៤ ម៉ោង | ១០ | | |



www.pheakdeylaw.com

| | | | | |
|---|---|---|---|---|
| | - ៤៥ % ឡើងទៅនៃចំនួនបន្ទប់ស្នាក់នៅ | ៦ | | |
| | - ក្រោម ៤៥ % នៃចំនួនបន្ទប់ស្នាក់នៅ | ៤ | | |
| ១១-១១ | + ការតុបតែងលំអ និងសំភារៈបំពាក់ក្នុងភោជនីយដ្ឋាន | | | |
| | - ល្អប្រណិត | ២០ | | |
| | - ល្អ | ១៥ | | |
| | - ល្អបង្គួរ | ១០ | | |
| | - មធ្យម | ៥ | | |
| ១១-១២ | + កំរិតសេវាបំរើក្នុងភោជនីយដ្ឋាន | | | |
| | - សេវាពេញលេញ ( Full Service ) | ២០ | | |
| | - សេវាមានកំរិត ( Limited Service ) | ១០ | | |
| ១១-១៣ | + មានបន្ទប់ពិសេស ( Private room ) | ៥ | | |
| ១១-១៤ | + មានបំរើម្ហូបក្នុងស្រុក | | | |
| | - មានម្ហូបច្រើនមុខ | ១០ | | |
| | - ចាប់ពី ៤មុខចុះ | ៥ | | |
| ១១-១៥ | + អនាម័យ | | | |
| | - ថែទាំល្អជាប្រចាំ និងគោរពតាមបទដ្ឋានបច្ចេកទេស | ១៥ | | |
| | - គោរពតាមបទដ្ឋានបច្ចេកទេស | ១០ | | |
| ១១-១៦ | + សណ្ឋាគារដែលប្រើប្រាស់ផលិតផលក្នុងស្រុកដែលមានគុណភាព និងអនាម័យល្អ | ១០ | | |
| **១២.** | ***សំភារៈបរិក្ខារសំរាប់សាលប្រជុំ/សាលជប់លៀង*** | | | |
| ១២-១ | + សំភារៈបរិក្ខារសំរាប់ប្រជុំ | | | |
| | - មានសាលប្រជុំធំទូលាយ និងបំពាក់ដោយឧបករណ៍ទំនើប បច្ចេកវិទ្យាខ្ពស់ | ១៥ | | |
| ១២-២ | + បន្ទប់ពិសេសសំរាប់ការប្រជុំ តូច និង មធ្យម ដែលអាចផ្ទុកភ្ញៀវបាន ២០នាក់យ៉ាងតិច | ១០ | | |
| ១២-៣ | + បន្ទប់ធំទូលាយសំរាប់ពិធីផ្សេងៗ | ១០ | | |



www.pheakdeylaw.com

| | | | | |
|---|---|---|---|---|
| ១២-៤ | + សំភារៈបរិក្ខារសំរាប់សោតទស្សន៍ | ៥ | | |
| ១២-៥ | + ការតុបតែងលំអក្នុងសាលប្រជុំ/ សាលជប់លៀង | | | |
| | - ល្អប្រណិត | ២០ | | |
| | - ល្អ | ១៥ | | |
| | - មធ្យម | ១០ | | |
| ១៣. | **ទីធ្លាសាធារណៈនៃសណ្ឋាគារ** | | | |
| ១៣-១ | + ច្រកចូល របៀង សាលធំ កន្លែងទទួលភ្ញៀវ និងច្រកចេញ-ចូលផ្សេងៗ | | | |
| | - តុបតែងល្អប្រណិតមានកន្លែងសំរាក អាន និងសរសេរ | ១៥ | | |
| | - តុបតែងល្អ រៀបចំការចេញ-ចូលមានរបៀប | ១០ | | |
| | - អនុវត្តតាមបទដ្ឋានការពារសុវត្ថិភាព និង បង្ការអគ្គីភ័យ | ៥ | | |
